ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

************

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣១៣

ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៩

សាលដីកា

លេខ : ១៣៧

ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

# នាមអាណាចក្ររាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២

ដោយមានសមាសភាពដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | យឹម | ម៉ុន្ណូ | ជាប្រធាន |
| ២- | លោក | ជីវ | កេង | ជាចៅក្រម |
| ៣- | លោក | ស៊ិន | ឌីម | ជាចៅក្រម របាយការណ៍ |
| ៤- | លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៥- | លោក | ប៉ែន | សាវឿន | ជាចៅក្រម |
| | | ក្រឡាបញ្ជី | | |
| | លោក | អ៊ូ | សុផុន | |
| | | តំណាងមហាអយ្យការ | | |
| | លោក | ឈួន | ចាន់ថា | ជាព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ២៥០ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ១៩៩៩ នៃ សំណុំរឿងរដ្ឋប្បវេណី លេខ ៤២៩ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

- រវាង ដើមចោទ អ្នកស្រី ឆេង ស៊ីម ជាចុងបណ្តឹងសាទុក្ខ អាយុ៤២ ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅសព្វថ្ងៃ ក្រុមទី ៨ ផ្លូវព្រះមុនីវង្ស សង្កាត់អូរឬស្សីទី៤ ខ័ណ្ឌ៧មករា ។ ឪពុកឈ្មោះ ឆេង ស្រេង "ស" ម្តាយឈ្មោះ ហ៊ី ម៉ៃ "ស" ប្តីឈ្មោះ សំ កុនសាន្ត ។

មានមេធាវី លោក គី តិច

- និងចុងចម្លើយ លោក សំ កុនសាន្ត ជាម្ចាស់បណ្តឹងសាទុក្ខ អាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅសព្វថ្ងៃ ក្រុមទី៤ មណ្ឌល២ សង្កាត់ ៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។ ឪពុកឈ្មោះ សំ សរ "ស" ម្តាយឈ្មោះ ម៉ម ភាច "ស" ប្រពន្ធឈ្មោះ ឆេង ស៊ីម ។

មានមេធាវី លោក ណុប បូផល

អំពីវិវាទ : ប្តឹងសុំផ្តាច់សមគ្គសង្វាស

បានឃើញបណ្តឹងសាទុក្ខលេខ ២៦៣ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់លោក

សំ ភុនសាន្ត ប្តឹងមិនសុខចិត្ត ពីសាលដីកា រដ្ឋប្បវេណី លេខ ២៥០ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ៣១៣ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៥-៨-៩៧ របស់ អ្នកស្រី ឆេង ស៊ីម បានប្តឹងសុំផ្តាច់សមគ្គសង្វាស ពីប្តីឈ្មោះ សំ ភុនសាន្ត ដោយអាងហេតុថា ចាប់តាំងពីឆ្នាំ ១៩៨៨ ខ្លួនបានយកគ្នាជាប្តីប្រពន្ធដោយមានរដ្ឋអំណាច ដឹងលឺត្រឹមត្រូវ ។ ចាប់តាំងពីរួមរស់ជាមួយគ្នា មកខ្លួនពុំដែលបានសេចក្តីសុខទេ ព្រោះប្តីខ្លួនចេះតែរករឿងឈ្លោះប្រកែក វាយជិ ជេរប្រមាថ ដល់ពូជអំបូរខ្លួន ម្យ៉ាងទៀតប្តីរបស់ខ្លួនបានយកលុយពីផ្ទះដើរចាយវាយ មិនគិតគូរដល់គ្រួសារទេ ហើយថែមទាំងចុះចេញពីផ្ទះ ដោយយកទ្រព្យសម្បត្តិមួយចំនួនទៅជាមួយ ដែលធ្វើឱ្យខ្លួនអស់មនោសញ្ចេតនា និង សុំចែកទ្រព្យសម្បត្តិរួម ។

បានឃើញ ដីកាសំរេចតាមពាក្យសុំលេខ ៧៩៥ គរ.៩៧ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៧ របស់តុលាការក្រុងព្រះសីហនុ ដែលបានសំរេច :

១- ទទួលពាក្យសុំរបស់លោកស្រី ឆេង ស៊ីម ចុះថ្ងៃទី ២៥ ខែ ៨ ឆ្នាំ ១៩៩៧ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ហាមលក់ ហាមដូរ ហាមបញ្ចាំ ហាមធ្វើប័ណ្ណកម្មសិទ្ធិ និង ការធ្វើអំណោយផ្សេងៗ នូវដីចំនួន ៥៥ ហិកតា ជាង ដែលស្ថិតនៅម្តុំពយ ម៉ាចូវ ក្នុងសង្កាត់ បិតត្រាំង ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ដែលជាកម្មសិទ្ធិរួមរបស់លោក សំ ភុនសាន្ត និង អ្នកស្រី ឆេង ស៊ីម ទុកជាបណ្តោះអាសន្នសិន រង់ចាំតុលាការសំរេចដល់អង្គសេចក្តី នៃ រឿង ។

៣- ដីកានេះ បើភាគីណាមួយមិនសុខចិត្ត មានសិទ្ធិប្តឹងមកតុលាការក្រុងព្រះសីហនុ យ៉ាងប្រញាប់បំផុត ។

៤- បង្គាប់មកលោកប្រធានភូមិបាលខ័ណ្ឌព្រៃនប់ និង លោកប្រធានស្សុរិយោដីក្រុងព្រះសីហនុ អនុវត្តដីកានេះ ឱ្យមានប្រសិទ្ធិភាព ។

បានឃើញ ដីកាសំរេចបញ្ចូលតតិយជនមកជាគូក្តី លេខ ១៤០ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៨ របស់ តុលាការក្រុងព្រះសីហនុ ដែលបានសំរេច :

១- បញ្ចូលឈ្មោះ អ្នកស្រី ប៊ុច រ៉ុង អាយុ ២៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី១៥ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

២- បញ្ចូលឈ្មោះអ្នកស្រី ថៃ អូន អាយុ ២៦ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី១១ សង្កាត់ផ្សារថ្មី ៣ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

៣- បញ្ចូលឈ្មោះ អ្នកស្រី ប៊ុច ជី អាយុ ២៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី៤៤ សង្កាត់អូរឫស្សីទី៣ ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ ។

ដែលមានប័ណ្ណកម្មសិទ្ធិនៅលើដីរបស់អ្នកស្រី នេង ស៊ីម និង លោក សំ ភុនសាន្ត ជាតតិយជនមកជាគូក្តីខាងចុងចម្លើយចាប់ពីពេលនេះតទៅ ។

បានឃើញ សាលក្រមរដ្ឋប្បវេណី លេខ ៥៩ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងព្រះសីហនុ សំរេចចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ឱ្យអ្នកស្រី នេង ស៊ីម និង លោក សំ ភុនសាន្ត ដាច់សមគ្គសង្វាសពីគ្នា ចាប់តាំងពីថ្ងៃសាលក្រមនេះ ក្លាយទៅជាសាលក្រមស្ថាពរតទៅ ។

៣- ឱ្យអ្នកស្រី នេង ស៊ីម ស្ថិតក្នុងភាពមេម៉ាយចំនួន ៣០០ ថ្ងៃ គិតចាប់តាំងពីថ្ងៃ បែកលំនៅសង្វាសតទៅ ។

៤- ទ្រព្យសម្បត្តិដីនៅចំណោតអូរក្រាវ មានប័ណ្ណកម្មសិទ្ធិលេខC1០១០៥ មានទំហំ ៥ហិកតា ដីស្ថិតនៅម្តុំពយព្រីង ពុំទាន់មានប័ណ្ណកម្មសិទ្ធិ មានទំហំ ៥៣៧.៣៨៩ម² ដោយគិតពីម្តុំពយព្រីងមកអាវផ្តៅ ផ្នែកខាងក្រោមជាប់សមុទ្រ ឯផ្នែកខាងលើភ្នំ ទៅទល់និង ផ្លូវឡាន រឺដេអូ មួយកំប្លេរ ចង្ក្រានហ្គាសមួយ ទូទឹកកកមួយគ្រឿង ម៉ាញ៉េមួយគ្រឿង និង សំភារៈប្រើប្រាស់ប្រចាំថ្ងៃប្រគល់ឱ្យអ្នកស្រី នេង ស៊ីម គ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ រីឯដីសង់លំនៅដ្ឋានមួយឡូត៍ស្ថិតនៅសង្កាត់៤ ខ័ណ្ឌមិត្តភាព ដីនៅម្តុំរោងចក្រប្រេងកាតទំហំ ៥ ហិកតា ៧០អា ពុំទាន់មានប័ណ្ណកម្មសិទ្ធិ ដីនៅម្តុំពយព្រីងចំនួន ៣០០.០០០ ម² ដែលសល់ពីដីដែលចែកឱ្យដើមចោទ សិប្បកម្មធ្វើទ្វា និងបង្អួច ០២ កន្លែង គឺ នៅភ្នំពេញមួយកន្លែង និង ក្រុងព្រះសីហនុមួយកន្លែង ម៉ាស៊ីនក្រឡឹងមួយគ្រឿង ម៉ាស៊ីនលាយស៊ីម៉ង់ត៍មួយគ្រឿង គ្រើយស្នូចមួយគ្រឿង ម៉ូតូ ០២គ្រឿង ប្រគល់ឱ្យលោក សំ ភុនសាន្ត គ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ គិតចាប់តាំងពីថ្ងៃ ដែលសាលក្រមនេះ ក្លាយជាសាលក្រមស្ថាពរតទៅ ។

៥- ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង ១៨០០ ៛ រង្វាន់ក្រឡាបញ្ជី ២០០៛ រង្វាន់អ្នកប្រគល់ដីការកោះ ៥.០០០៛ សរុប ៧.០០០៛ តែប្រាក់នេះ បានកាត់យកពីប្រាក់ ៧០០០៛ ដែលដើមចោទបានបង់ទុករួចហើយ កាលបើជុំតឧទ្ធរណ៍ ទើបបង្គាប់ឱ្យចុងចម្លើយបង់សងទៅដើមចោទជាក្រោយ ។

៦- សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ទុកសិទ្ធិឱ្យគូភាគីប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ លេខ ៣២ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់លោក សំ ភុនសាន្ត ប្តឹងមិនសុខចិត្ត នឹង សាលក្រមលេខ ៥៩ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងព្រះសីហនុ លើគ្រប់ចំណុចទាំងស្រុង នៃ សាលក្រម ។

បានឃើញ សាលដីការដ្ឋប្បវេណី លេខ ៣១ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខមេធាវីដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥-៩-៩៨ របស់ឈ្មោះ សំ ភុនសាន្ត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៥៩ ចុះថ្ងៃទី ២៦-៦-៩៨ របស់តុលាការក្រុងព្រះសីហនុ ទុកជាបានការដដែល ។

៣- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛០០ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹង ២៥៥០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛០០ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛០០ និង លើអាជ្ញាធរតុលាការ ៥.០០០៛០០ សរុប ១៣.០០០៛០០ ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់ និង សាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងទាស់លេខ ០៦ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ របស់លោក សំ ភុនសាន្ត ( បានទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២៧-០១-៩៩ ) ប្តឹងមិនសុខចិត្ត នឹងសាលដីកា រដ្ឋប្បវេណី លេខ ៣១ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណី លេខ ២៥០ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃ សេចក្តី សំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ០១-០២-៩៩ របស់ឈ្មោះ សំ ភុនសាន្ត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះ នឹង គតិច្បាប់ ។

២- តំកល់សាលដីកាកំបាំងមុខលេខ ៣១ ចុះថ្ងៃទី ១៩-០១-៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ តែទុកដូចជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ២៦៣ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់លោក សំ ភុនសាន្ត ប្តឹងមិនសុខចិត្ត នឹងសាលដីកា រដ្ឋប្បវេណី លេខ ២៥០ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ១៦-០៣-២០០០ របស់លោក សំ ភុនសាន្ត

បានឃើញ សារណាតប ចុះថ្ងៃទី ១៣-១២-២០០០ របស់អ្នកស្រី ឆេង ស៊ីម

បានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា :

រឿងនេះ ជាវិវាទ ប្តឹងសុំផ្តាច់សមគ្គសង្វាស ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សំ កុនសាន្ត ឆ្លើយថា : ទំនាក់ទំនងស្នេហារវាងខ្លួន និងអ្នកស្រី ឆេង ស៊ីម មានកំរិតត្រឹមតែជាស្រីកំណាន់ចិត្តលួចលាក់តែប៉ុណ្ណោះ ខ្លួនពុំដែលបានរៀបចំពិធីអាពាហ៍ពិពាហ៍ ឬ ក៏ចុះចំណងអាពាហ៍ពិពាហ៍ នៅកន្លែងរដ្ឋអំណាចអាត្រានុកូលដ្ឋានម្តងណាទេ ។

ចំពោះការដែលអ្នកស្រី ឆេង ស៊ីម ថា គាត់បានរួបខ្លួនជាប្តី តាំងពីឆ្នាំ ១៩៨៨ ដោយមានពិធីសែនព្រេនផងនោះ គឺជាការនិយាយកុហក ព្រោះថា នៅឆ្នាំ១៩៨៨ ប្រពន្ធដើមរបស់ខ្លួន ឈ្មោះ នូ - សៅយុត បានរស់នៅជាមួយខ្លួនជាប់ជានិច្ច ដោយរូបខ្លួនជាប្រធានរោងចក្រទឹកកកសម័យកម្ពុជាប្រជាមានិតជាសម័យសង្គមនិយម តើកម្មាភិបាល ណាមួយដែលរដ្ឋអនុញ្ញាតឱ្យយកប្រពន្ធពីរនោះ គឺពុំអាចមានលទ្ធភាពទាល់តែសោះ ។ ហើយអ្នកស្រី ឆេង ស៊ីម ក៏មានប្តីដែរ ។

ចំពោះដី នៅពយព្រីង និង ដី នៅក្បែររោងចក្រប្រេងកាត ដែលអ្នកស្រីប្តឹងទាមទារនោះក៏ជារបស់លោក ទៀ សុទ្ធ, លោក អោក សារ៉ាត, លោក ឈឹម ហួ និង លោក ខួត ប៊ុតឌី ដែរ ។

ក្រឡាបញ្ជីអាន សារណាតប របស់អ្នកស្រី ឆេង ស៊ីម ។

លោក ណុប បូផល មេធាវីការពារឱ្យចុងចម្លើយ ធ្វើសេចក្តីសន្និដ្ឋានថា : ការទំនាស់គឺ លើដីមួយកន្លែង គ្មានកម្មសិទ្ធិ ហើយនោះ ពុំដល់ ៨០ ហិកតាទេ គឺ ប្រហែល ៤០ ហិកតា ទេ ។ ហើយសាលាឧទ្ធរណ៍សំរេចចូលដីរបស់គេ ។ ហើយការដែលដើមចោទទាមទារទ្រព្យរួមនោះ ក៏ពុំត្រឹមត្រូវដែរ ព្រោះថា នៅឆ្នាំ១៩៨៨ លោក សំ កុនសាន្ត មានប្រពន្ធត្រឹមត្រូវ ហើយអ្នកស្រី ឆេង គីម ក៏មានប្តីដែរ។

ដូច្នេះ ខ្ញុំសុំឱ្យក្រុមប្រឹក្សាជំនុំជំរះ ពិចារណាអំពីចំណងអាពាហ៍ពិពាហ៍ និង សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ។

លោក គី តិច មេធាវីការពារឱ្យដើមចោទ ធ្វើសេចក្តីសន្និដ្ឋានថា : ឈ្មោះ សំ កុនសាន្ត និងអ្នកស្រី ឆេង ស៊ីម ជាប្តីប្រពន្ធ និងគ្នា ដោយមានចាស់ទុំដឹងឮ ដោយមានការសែនព្រេន និង រដ្ឋអំណាចទទួលស្គាល់ ។ ម្យ៉ាងទៀត ក្នុងប្រវត្តិរូបរបស់ លោក សំ កុនសាន្ត ក៏ដាក់ឈ្មោះ ឆេង គីម ដែរ ចំណែកប្រពន្ធដើមគាត់ឈ្មោះ នូ សៅយុត ។ ដូច្នេះឈ្មោះ ឆេង គីម វាដូចគ្នានឹងឈ្មោះ ឆេង ស៊ីម ។

អាស្រ័យហេតុនេះ ខ្ញុំសូមឱ្យឯកឧត្តមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្ដាប់ចម្លើយរបស់លោក សំ កុនសាន្ត , សារណារបស់អ្នកស្រី ឆេង ស៊ីម និង សេចក្ដីសន្និដ្ឋានរបស់មេធាវី នៃ គូភាគី
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

# តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ២៦៣ ចុះថ្ងៃទី ៣០-៧-៩៩ របស់លោក សំ កុនសាន្ត ស្ថិតក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃ ច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី។

- យល់ឃើញថា ការដែលលោក សំ កុនសាន្ត លើកឡើងក្នុងសារណារបស់លោក និង ក្នុងពេលសវនាការនេះ ថា លោក និង អ្នកស្រី ឆេង ស៊ីម ពុំមានចំណងអាពាហ៍ពិពាហ៍ តាមផ្លូវច្បាប់ទេ គឺជា ស្រីកំណាន់បែបអនីតិសង្វាសនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ចូលជាធរមាននៅឆ្នាំ១៩៨៩ ហើយលោក និង អ្នកស្រី ឆេង ស៊ីម រួមរស់ជាមួយគ្នា នៅឆ្នាំ១៩៨៨ ឬ ១៩៨៩ ដូច្នេះនៅពេលនោះ ពុំទាន់មានសៀវភៅចុះអាពាហ៍ពិពាហ៍ទេ ។ ប៉ុន្ដែ ទោះបីពុំបានចុះអាពាហ៍ពិពាហ៍ ក៏ប៉ុន្ដែ លោក សំ កុនសាន្ត បានទទួលស្គាល់នូវ ចំណងអាពាហ៍ពិពាហ៍នេះ ច្បាស់លាស់ណាស់នៅក្នុង កំណត់ហេតុ ផ្សះផ្សា ចុះថ្ងៃទី ២៨-៣-៩៤ មុខតុលាការក្រុងព្រះសីហនុ ថា ការប្ដឹងសុំផ្ដាច់សមគ្គសង្វាស របស់ប្រពន្ធលោក លោកមិនទាន់អស់មនោសញ្ចេតនាពីប្រពន្ធលោកទេ ពីព្រោះលោក នៅតែស្រលាញ់ប្រពន្ធ របស់លោកដដែល លោកបានគ្នាជាប្ដីប្រពន្ធនេះ ដោយលំបាកលំបិនណាស់ មានចំណងអនុស្សាវរីយ៍ ដែល មិនអាចបំភ្លេចបាន ដូច្នេះលោក សុំបន្ដរួមរស់ ជាមួយប្រពន្ធរបស់លោកបន្ដទៀត ហើយប្រវត្តិរូប ដែលលោក សរសេរដោយផ្ទាល់ខ្លួនលោកនៅឆ្នាំ១៩៩៣ ក៏លោកបញ្ជាក់ដែរថា អ្នកស្រីឆេង ស៊ីម ជាប្រពន្ធរបស់លោក។

- យល់ឃើញថា ការដែលលោក សំ កុនសាន្ត លើកឡើងនៅក្នុងសារណា ក៏ដូចជានៅ ពេលសវនាការនេះដែរ ដែលថា លោកពុំសុខចិត្តប្រគល់ដីនៅភូមិអូរក្រាវ ចំនួន ០៥ ហិកតា ដែលមានប័ណ្ណ សំគាល់សិទ្ធិលេខ $C_1$ ០១០៥ និង ដី នៅពយព្រីង ឃុំបិតត្រាង ឱ្យទៅអ្នកស្រី ឆេង ស៊ីម ដោយហេតុថា ដីនេះ មិនមែនជាទ្រព្យសម្បត្តិរួមទេ គឺជាដីដែលលោកទិញ ដោយប្រាក់ដើមរបស់លោក បានមកពីការលក់ ដីរួម ជាមួយសពប្រពន្ធមុនរបស់លោកនោះ ពុំមានភស្ដុតាងគួរឱ្យជឿបានឡើយ ពីព្រោះដីនេះទិញនៅក្នុង ចំណងអាពាហ៍ពិពាហ៍ជាមួយអ្នកស្រី ឆេង ស៊ីម ហើយពុំមានភស្ដុតាងណាបញ្ជាក់ថា លុយទិញដីនេះ ជាលុយ ទ្រព្យដើមរបស់លោកទេ ។

- យល់ឃើញថា ទ្រព្យសម្បត្តិ ដែលតុលាការបានប្រគល់ឱ្យលោក សំ កុនសាន្ត ហើយដែល កំពុងស្ថិតនៅលើដៃរបស់លោក សំ កុនសាន្ត មានចំនួនច្រើនជាងទ្រព្យសម្បត្តិ ដែលតុលាការបានប្រគល់ឱ្យ អ្នកស្រី ឆេង ស៊ីម មែន ប៉ុន្ដែ អ្នកស្រី ឆេង ស៊ីម ពុំបានទាមទារអ្វីលើសពីនេះដែរ លើកលែងតែ ដីនៅ ពយព្រីងដែលពុំទាន់ស្ថិតនៅក្នុងការកាន់កាប់របស់ភាគីណា ដែលអ្នកស្រី ឆេង ស៊ីម ទាមទារចំណែកលើស

ពីពាក់កណ្ដាល ។ ដូច្នេះ ការសំរេចសេចក្ដីរបស់តុលាការថ្នាក់ក្រោម មានលក្ខណៈត្រឹមត្រូវតាមសមធមិហើយ ។

- យល់ឃើញថា ការដែលលោក សំ ភុនសាន្ត លើកឡើងនៅក្នុងពេលសវនាការនេះថា ដីនៅពយព្រីង មានតែជាង ៥០ ហិកតា ទេ ក្រៅពីនោះសុទ្ធតែជាដីគេ តើហេតុអ្វី តុលាការបាន ដីជាង ៨០ ហិកតា យកមកធ្វើការបែងចែក នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះ តុលាការសំរេចបែងចែកដូចនេះ ដោយហេតុថា មន្ត្រីតុលាការបានសហការជាមួយភូមិបាល ខ័ណ្ឌ ព្រៃនប់ និង ចៅសង្កាត់រងបិតត្រាំង បានចុះវាស់វែងដីទំនាស់នេះ តាមកំណត់ហេតុ ចុះថ្ងៃទី ១៧-០១-៩៨ និង តាមប្លង់ ចុះថ្ងៃទី ២១-០១-៩៨ (ឯកសារលេខ១៨) ឃើញថា ក្នុងរង្វង់ទីតាំងដីទំនាស់នេះ មានផ្ទៃក្រឡា៤៤៥.៨៥៦ម $^២$ +២០៨.៥៣៨ ម $^២$ + ១៣៥.០០០ ម $^២$ + ៤៧.៩៩៥ ម $^២$ = ៨៣៧.៣៨៩ ម $^២$ គឺ ត្រឹមត្រូវតាមទំហំដី ដែលតុលាការថ្នាក់ក្រោម បានលើកយកមកធ្វើការបែងចែកហើយ ។

- យល់ឃើញថា ការដែលលោក សំ ភុនសាន្ត លើកឡើងថា ដីចំនួន ៣០០.០០០ ម $^២$ នៅពយព្រីង ដែលតុលាការថ្នាក់ក្រោមប្រគល់ឱ្យលោកនេះ គឺជាដីអ្នកដទៃ លោកពុំអាចទទួលយកបានទេ នោះគឺជាការពុំត្រឹមត្រូវទេ ពីព្រោះនៅលើគំនូសប្លង់ ចុះថ្ងៃទី ២១-០១-៩៨ ( ឯកសារលេខ ១៨ ) ដែលតុលាការទទួលស្គាល់ នៅក្នុងរង្វង់ដីទំនាស់ មានឃើញដីកម្មសិទ្ធិរបស់ឈ្មោះ ប៊ុច រ៉ុង ទំហំ ១៣៥.០០០ ម $^២$ + ៤៧.៩៩៥ ម $^២$ = ១៨២.៩៩៥ ម $^២$ តែប៉ុណ្ណោះ ហើយតុលាការមុននឹងសំរេចសេចក្ដីក្នុងរឿងក្ដីនេះ ក៏បានចាត់បញ្ចូលឈ្មោះ ប៊ុច រ៉ុង មកជា តតីយជន ខាងចុងចម្លើយរួចហើយ តាមដីកាសំរេចលេខ ១៤០ ចុះថ្ងៃទី ០៤-០៣-៩៨ និង បានកោះហៅឈ្មោះ ប៊ុច រ៉ុង និង អ្នកពាក់ព័ន្ធ ពីរនាក់ទៀត តាមដីកាកោះ ចុះថ្ងៃទី ០៦-០៣-៩៨ មកបំភ្លឺដែរ ប៉ុន្តែសាម៉ីខ្លួនពុំបានចូលខ្លួនមកតុលាការទេ ហើយក៏ពុំមានការប្ដឹងទាស់ ឬ ប្ដឹងឧទ្ធរណ៍ដែរ ។ ដូច្នេះបើនៅពេលអនុវត្តសាលដីកា មានតតីយជនមក ប្ដឹងទាស់ តុលាការអាចលើកយកដីនៅពយព្រីង ទាំងចំណែកត្រូវបានទៅលោក សំ ភុនសាន្ត ទាំងចំណែកត្រូវបានទៅខាងអ្នកស្រី ឆេង ស៊ីម មកពិចារណា និង សំរេចជាថ្មីបាន។ ប៉ុន្តែក្នុងករណីដែល គ្មានការប្ដឹងទាស់ទេ តុលាការត្រូវតម្កល់ នៅទំហំដីនេះ ទុកជាបានការ ។

- យល់ឃើញថា អ្នកស្រី ឆេង ស៊ីម បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវី មកចូលរួម ដូច្នេះ តុលាការកំពូល ជំនុំជំរះ កំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណី លេខ ២៥០ ចុះថ្ងៃទី ២០-០៥-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទំរង់ និង គតិច្បាប់ហើយ ។

# ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខលោក សំ ភុនសាន្ត កំបាំងមុខ អ្នកស្រី ឆេង ស៊ីម ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ២៦៣ ចុះថ្ងៃទី ៣០-០៧-៩៩ របស់លោក សំ ភុនសាន្ត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាវដ្តប្បវេណី លេខ ២៥០ ចុះថ្ងៃទី ២០-០៥-៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ដែល លោក សំ ភុនសាន្ត បានបង់ទុកនៅតុលាការកំពូល ចំនួន ១៩០០០៛០០ គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ៤០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៤០០៛០០ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,
- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ។

៤- សាលដីកានេះ ជំនុំជំរះ នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ ។